# វិស័យអាទិភាព ក្នុងការបែងចែកថវិកាជាតិ ឆ្នាំ២០១៧



ប្រភព÷ បទឧទ្ទេសនាមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱកាសពិភាក្សាសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧, រដ្ឋសភា

ចងក្រងដោយ÷ នាយកដ្ឋានព័ត៌មានវិទ្យា អគ្គលេខាធិការដ្ឋានកសហវ

# សង្គមកិច្ច គឺជាវិស័យអាទិភាពទីមួយ
# ក្នុង ឆ្នាំ២០១៧ នេះ

ការយកចិត្តទុកដាក់ត្រូវផ្តោតជាពិសេសលើក្រសួងអាទិភាព ចំនួន៣គឺ÷

## ក្រសួងសុខាភិបាល

## ក្រសួងអប់រំ យុវជន និងកីឡា

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ទំហំចំណាយចរន្តវិស័យនេះកើនឡើងច្រើនជាងគេ។ ថវិកាគ្រោង÷

៤ ៨៣៦ ៤៩៨ លានរៀល សមមូលប្រមាណ ១ ១៩៤ លានដុល្លារអាមេរិក

- GDP ៥,៤៣ % នៃផលិតផលក្នុងស្រុកសរុប ២០១៧
- ១២,៧ % កើនឡើងធៀបនឹងច្បាប់ឆ្នាំ ២០១៦

# ក្រសួងអប់រំ យុវជន និងកីឡា

ថវិកាគ្រោង៖ ២ ៧៣៩ ៩១៣ លានរៀល សមមូលប្រមាណ ៦៧៧ លានដុល្លារអាមេរិក

៣,០៨ % នៃផលិតផលក្នុងស្រុកសរុប ២០១៧

២៤,២ % កើនឡើងធៀបនឹងច្បាប់ឆ្នាំ ២០១៦

- គិតគូរទៅដល់ការដំឡើងប្រាក់បៀវត្សជូនគ្រូបង្រៀន និងបុគ្គលិកសិក្សា
- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅកម្រិតចំណេះទូទៅ ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា ពិសេសដើម្បីផ្តល់ឱកាសដល់សិស្សក្រីក្រ
- បន្តគាំទ្រការសាងសង់បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាតនៅតាមសាលារៀន
- ពង្រឹងការកែទម្រង់ការប្រឡង កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល
- បង្កើនការចុះឈ្មោះចូលរៀនលើមុខវិជ្ជាវិទ្យាសាស្ត្រពិត បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា (ជំនាញ STEM)
- បង្កើតវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ផ្តល់ជម្រើសដល់សិស្សចប់ មធ្យមសិក្សាបឋមភូមិ អាចមានលទ្ធភាពបន្តការសិក្សាជំនាញបច្ចេកទេស ដែលអាចរកការងារធ្វើបាន
- លើកកម្ពស់ការអប់រំកាយ និងកីឡា បណ្តុះបណ្តាលកីឡាករ ត្រៀមទទួលធ្វើម្ចាស់ផ្ទះនៃការប្រកួត កីឡាស៊ីហ្គេមនៅឆ្នាំ២០២៣។

# ក្រសួងសុខាភិបាល

ថវិកាគ្រោង÷ ១ ៦៩៧ ៦១៥ លានរៀល សមមូលប្រមាណ ៤១៩ លានដុល្លារអាមេរិក

GDP ១,៩១ % នៃផលិតផលក្នុងស្រុកសរុប ២០១៧

១៩,៣ % កើនឡើងធៀបនឹងច្បាប់ឆ្នាំ ២០១៦

FUNDING គាំទ្រដល់កម្មវិធីមូលនិធិសមធម៌ឱ្យមានប្រសិទ្ធភាពនៅទូទាំងប្រទេស ដើម្បីផ្តល់សេវាព្យាបាលឥតគិតថ្លៃជូនដល់ ប្រជាជនក្រីក្រ

បង្កើនកញ្ចប់ថវិកាប្រតិបត្តិការជូនទៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពដោយផ្ទាល់ សម្រាប់បង់ថ្លៃសេវាព្យាបាលជូនប្រជាពលរដ្ឋ ដែលគ្មានលទ្ធភាព និងបង្កើនប្រសិទ្ធភាព នៃការផ្តល់សេវានៅនឹងកន្លែង

វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ការបំពាក់សម្ភារៈបរិក្ខារបច្ចេកទេសចាំបាច់ និងបង្កើនការផ្គត់ផ្គង់ឱសថ ដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាព

បង្កើនការគាំទ្រដល់ប្រតិបត្តិការរបស់មន្ទីរពេទ្យគន្ធបុប្ផាជាបណ្តើរៗ ដើម្បីធានាបានថា មន្ទីរពេទ្យនេះនៅតែអាចរក្សាបាននូវស្តង់ដារគុណភាព និងការផ្តល់សេវាព្យាបាលដោយឥតគិតថ្លៃ នៅពេលផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋពេញលេញ។ FREE

# វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់

## ក្នុង ឆ្នាំ២០១៧ នេះ

វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
គ្របដណ្តប់លើក្រសួងចំនួន ០៣ គឺ÷

**ក្រសួងការពារជាតិ**

**ក្រសួងមហាផ្ទៃ**

**ក្រសួងយុត្តិធម៌**

ថវិកាគ្រោង÷ ៣ ៤៤១ ៥២៣ លានរៀល សមមូលប្រមាណ ៨៥០ លានដុល្លារអាមេរិក

ចំណាយបន្ទុកបុគ្គលិកមានចំនួនរហូតទៅដល់ ៧៧,៨% នៃចំណាយចរន្តវិស័យ

- GDP ៣,៨៧ % នៃផលិតផលក្នុងស្រុកសរុប ២០១៧
- ២១,០ % កើនឡើងធៀបនឹងច្បាប់ឆ្នាំ ២០១៦

# វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់

នៅឆ្នាំ ២០១៧ វិស័យនេះនឹងផ្តល់អាទិភាពជាសំខាន់ផ្តោតទៅលើ÷

- បង្កើនការគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ
- បន្តផ្តល់ថវិកាការពារក្តីជូនគណៈមេធាវីកម្ពុជា ដើម្បីផ្តល់សេវាការពារក្តីឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ
- បង្កើនការគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- ផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខមាលភាពកងកម្លាំងប្រដាប់អាវុធ រួមទាំងការហ្វឹកហ្វឺន និងការបំពាក់មធ្យោបាយចាំបាច់នានា ក្នុងបុព្វហេតុបន្តធានាកិច្ចការពារប្រកបដោយប្រសិទ្ធភាពនូវអធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងភាពសុខក្សេមក្សាន្តរបស់ប្រជាជន
- បង្កើនការគាំទ្រដល់ការបណ្តុះបណ្តាលមន្ត្រីនគរបាល និងមន្ត្រីពន្ធនាគារ ព្រមទាំងផ្តល់ការលើកទឹកចិត្តដល់នគរបាលចរាចរណ៍ និងនគរបាលទេសចរណ៍
- បន្តគាំទ្រដល់ប្រតិបត្តិការផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋ
- គាំទ្រសកម្មភាពការងារកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន ព្រមទាំងរៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន តាមគ្រប់មាត់ច្រកទូទាំងប្រទេស
- បន្តគាំទ្រការអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព។

# វិស័យរដ្ឋបាលទូទៅ

ថវិកាគ្រោង÷ ១ ៩៨៦ ៩៤២ លានរៀល សមមូលប្រមាណ ៤៩១ លានដុល្លារអាមេរិក

២,២៣ % នៃផលិតផលក្នុងស្រុកសរុប ២០១៧

២៤,៤ % កើនឡើងធៀបនឹងច្បាប់ឆ្នាំ ២០១៦

នៅឆ្នាំ ២០១៧ វិស័យនេះនឹងផ្តល់អាទិភាពជាសំខាន់ផ្តោតទៅលើ÷

- ការចុះឈ្មោះ ពិនិត្យបញ្ជីឈ្មោះ និងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ ព្រមទាំងការចុះឈ្មោះបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ ២០១៨
- គាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ជំរុញការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីរដ្ឋ ឯកជន និងសហគមន៍ជនជាតិដើមភាគតិច
- បង្កើនប្រសិទ្ធភាពនៃកិច្ចការទូត ដោយបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មន្ត្រីការទូតដែលកំពុងបំពេញភារកិច្ចនៅក្រៅប្រទេស
- គាំទ្រដល់កិច្ចការពារ និងជួយសង្គ្រោះពលករខ្មែរធ្វើការនៅក្រៅប្រទេស ជាពិសេសស្ត្រីខ្មែរដែលត្រូវរងគ្រោះដោយការឆបោក និងជួញដូរផ្លូវភេទជាដើម។



# វិស័យសេដ្ឋកិច្ច

ថវិកាគ្រោង៖ ១ ៣០៦ ៣៦៧ លានរៀល សមមូលប្រមាណ ៣២៣ លានដុល្លារអាមេរិក

GDP ១,៤១ % នៃផលិតផលក្នុងស្រុកសរុប ២០១៧

១៣,១ % កើនឡើងធៀបនឹងឆ្នាំ ២០១៦

បើទោះជាក្រសួងសំខាន់ៗក្នុងវិស័យនេះមិនបានទទួលនូវកំណើនចំណាយចរន្ត ថវិកាថ្នាក់ជាតិច្រើន និងនៅមានទំហំតូចក្តី ក្រសួងសំខាន់ៗទាំងនេះដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, និងក្រសួងសាធារណការ និងដឹកជញ្ជូន គឺជាស្ថាប័ន ដែលស្រូបយកចំណាយវិនិយោគ ផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេស រហូតដល់ ទៅជាង ៧០ % សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចជា ផ្លូវ ស្ពាន និងប្រព័ន្ធធារាសាស្ត្រជាដើម។



# សូមអរគុណ

ផលិតដោយនាយកដ្ឋានព័ត៌មានវិទ្យា
អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ